# សំនួរជាច្រើនដែលអ្នកចាប់អារម្មណ៍តែងតែសួរ

## បើសិនជាព្រះមានសេចក្ដីស្រឡាញ់ ហេតុអ្វីទ្រង់អនុញ្ញាតឱ្យមានអំពើអាក្រក់ជួជាតិ?



**ព្រះទ្រង់**បានអនុញ្ញាតឱ្យមានអំពើអាក្រក់ជួជាតិ ហើយមនុស្សរាប់លាននាក់នៅលើផែនដីនេះ កំពុងតែប្រព្រឹត្តអំពើនេះដោយចេតនា។ ឧទាហរណ៍ ពួកគេប្រកាសសង្គ្រាម ទំលាក់គ្រាប់បែកទៅលើកូនក្មេង បង្ខូចផែនដី ហើយបណ្ដាលឱ្យមានទុរភិក្សជាដើម។ មនុស្សរាប់លាននាក់ជក់បារីហើយកើតរោគមហារីកខាងសួត។ គេតែងតែប្រព្រឹត្តអំពើកំផិតហើយកើតកាមរោគ។ គេពិសាស្រាហើយកើតជម្ងឺថ្លើមម្យ៉ាង ជាដើម។ មនុស្សបែបនេះពិតជាមិនប្រាថ្នាចង់ឱ្យអំពើអាក្រក់ជួជាតិគ្រប់ប្រភេទឈប់នោះទេ។ ពួកគេប្រាថ្នាចង់បំបាត់តែពិន័យដែលជាលទ្ធផលនៃអំពើទាំងនោះប៉ុណ្ណោះ។ កាលណាពួកគេច្រូតបានពូជដែលគេបានព្រោះពីមុននោះ។ ពួកគេស្រែកឡើងថា: «ហេតុអ្វីបានកើតមកលើខ្ញុំអ៊ីចឹង?»។ ហើយគេបន្ទោសលើព្រះ ដូចជាសុភាសិត ១៩:៣ បានចែងថា: «សេចក្ដីចំកួតរបស់មនុស្ស រមែងបង្ខូចផ្លូវខ្លួនទៅ ហើយអ្នកនោះក៏អន់ចិត្តចំពោះព្រះយេហូវ៉ាដែរ»។ ហើយបើសិនជាព្រះបានបញ្ចប់នូវការប្រព្រឹត្តដ៏អាក្រក់របស់គេ ពួកគេនឹងតវ៉ាថាគេបានបាត់សេរីភាពរបស់គេឱ្យប្រព្រឹត្តការនោះ!

មូលហេតុសំខាន់បំផុតរបស់ព្រះយេហូវ៉ាចំពោះការអនុញ្ញាតឱ្យមានអំពើអាក្រក់ គឺថាដើម្បីតបឆ្លើយនិងដោះស្រាយការចោទប្រឆាំងរបស់អារក្សសាតាំង។ អារក្សសាតាំងបានចោទថា គ្មានមនុស្សដែលនៅផែនដីអាចរក្សាចិត្តស្មោះគ្រប់លក្ខណ៍ចំពោះទ្រង់នៅក្រោមការល្បងលបានឡើយ។ (យ៉ូប ១:៦–១២; ២:១–១០) ព្រះយេហូវ៉ាបានអនុញ្ញាតឱ្យអារក្សសាតាំងនៅរស់ ដើម្បីឱ្យវាមានឱកាសនឹងបង្ហាញសក្ខីភាព ថាតើចំណោទប្រឆាំងរបស់វាជារឿងត្រូវឬមិនត្រូវ។ (និក្ខមនំ ៩:១៦) សាតាំងកំពុងតែនាំឱ្យមានសេចក្ដីទុក្ខវេទនារហូតដល់ឥឡូវនេះ ដើម្បីជំរុញឱ្យមនុស្សបែរប្រឆាំងនឹងព្រះ កាលដែលវាខ្នះខ្នែងបង្ហាញសក្ខីភាពចំពោះការចោទប្រឆាំងរបស់វានោះ។ (វិវរណៈ ១២:១២) យ៉ាងណាក៏ដោយ លោកយ៉ូបបានរក្សាចិត្តស្មោះគ្រប់លក្ខ័ណ៍ចំពោះព្រះ។ ព្រះយេស៊ូក៏បានធ្វើអ៊ីចឹងដែរ។ ពួកគ្រីស្ទានពិតសព្វថ្ងៃនេះក៏កំពុងធ្វើដូច្នោះដែរ។–យ៉ូប ២៧:៦; ម៉ាថាយ ៤:១–១១; ពេត្រុសទី១ ១:៦, ៧

**ខ្ញុំចង់ជឿទៅលើសួនមនោរម្យនៅលើផែនដីដែលនៅទីនោះមនុស្សអាចនៅជានិរន្តរ៍ ក៏ប៉ុន្តែ តើរឿងនេះមិនជាការល្ងង់ហួសហេតុនឹងជឿថាអាចមានទេឬ?**

មិនមែនទេ យោងទៅតាមព្រះគម្ពីរ ។ សេចក្ដីសន្យានេះមើលទៅហាក់ដូចជាការល្ហួសពីលទ្ធភាពនឹងទៅជាការពិត គឺព្រោះតែមនុស្សបានជួបប្រទះតែសេចក្ដីអាក្រក់ជាច្រើនសតវត្សមកហើយ ។ ព្រះយេហូវ៉ាបានបង្កើតផែនដី ហើយមានបន្ទូលប្រាប់មនុស្សលោកឱ្យបំពេញផែនដីទាំងមូលដោយមនុស្សប្រុសនិងស្រីដ៏សុចរិត ដែលនឹងថែរក្សាសត្វនានានិងរុក្ខជាតិទាំងឡាយ ព្រមទាំងរក្សាទុកសោភ័ណភាពនៃផែនដី ជាជាងបំផ្លាញទៅវិញនោះ ។ (សូមមើលទំព័រ១២និង១៧) សួនមនោរម្យដែលបានសន្យាមកមិនមែនល្ហួសលទ្ធភាពនឹងទៅជាការពិតនោះទេ ។ ផ្ទុយទៅវិញនោះ ស្ថានភាពដ៏គួរឱ្យស្ដាយទាំងនេះជាការអាក្រក់ហួសពេក ដែលមិនគួរមានតទៅទៀតឡើយ ។ សួនមនោរម្យនឹងមានជំនួសសេចក្ដីអាក្រក់ទាំងនេះវិញ ។

**តើខ្ញុំអាចឆ្លើយបានយ៉ាងណា ចំពោះមនុស្សដែលចំអកហើយនិយាយថា ព្រះគម្ពីរជារឿងព្រេងហើយមិនស្របនឹងវិទ្យាសាស្ត្រ?**

ជំនឿទៅលើសេចក្ដីសន្យាទាំងនេះ មិនមែនជាភាពងាយជឿឡើយ ។ «សេចក្ដីជំនឿកើតឡើងដោយឮ» ។ ដោយការសិក្សាព្រះបន្ទូលរបស់ព្រះ មនុស្សម្នាក់អាចយល់ឃើញនូវប្រាជ្ញារបស់ព្រះគម្ពីរនោះយ៉ាងជាក់ស្ដែងមែន និងឃើញថាជំនឿអាចលូតលាស់បាន ។–រ៉ូម ១០:១៧; ហេព្រើរ ១១:១

ការស្រាវជ្រាវវត្ថុបុរាណខាងព្រះគម្ពីរជួយបង្ហាញភាពត្រឹមត្រូវជាច្រើននៃប្រវត្តិសាស្ត្រនៃព្រះគម្ពីរ ។ វិទ្យាសាស្ត្រដ៏ពិតប្រាកដមានភាពស្របតាមព្រះគម្ពីរ ។ សេចក្ដីពិតបន្តបន្ទាប់មកនេះ បានត្រូវចែងទុកនៅក្នុងព្រះគម្ពីរជាយូរយារមុនដែលវិជ្ជាកររបស់លោកីយ៍បានរកឃើញការនេះទៅទៀត ដូចជា: លំដាប់នៃដំណាក់ការលូតលាស់របស់ផែនដីនៅពេលដំបូងនោះ ផែនដីមានរាងមូលហើយបានត្រូវព្យួរនៅលើទទេ ហើយហេតុការណ៍ដែលថាសត្វស្លាបផ្លាស់លំនៅតាមរដូវ ។–លោកុប្បត្តិ ជំពូកទី១; អេសាយ ៤០:២២; យ៉ូប ២៦:៧; យេរេមា ៨:៧

ការសម្រេចនៃបទទំនាយជាច្រើនសម្ដែងថា ព្រះគម្ពីរជាលទ្ធផលនៃវិញ្ញាណបរិសុទ្ធរបស់ព្រះ ។ ព្យាការីដានីយ៉ែលបានទាយទុកជាមុន អំពីការកើនឡើងនិងការធ្លាក់ចុះរបស់មហាអំណាចនៃលោកីយ៍ ហើយថែមទាំងពេលវេលាដែលព្រះមេស្ស៊ីនឹងត្រូវយាងមកនិងត្រូវគេធ្វើគុតទ្រង់ទៀតផង ។ (ដានីយ៉ែល ជំពូកទី២និងទី៨; ៩:២៤–២៧) សព្វថ្ងៃនេះ បទទំនាយជាច្រើនឯទៀតកំពុងតែសម្រេចនៅឡើយ ដែលសម្ដែងថាគ្រានេះជា «ជាន់ក្រោយបង្អស់» ។ (ធីម៉ូថេទី២ ៣:១–៥; ម៉ាថាយ ជំពូកទី២៤)

ការដឹងនូវអនាគតពីមុនបែបនេះ មិនមែនមកពីសមត្ថភាពរបស់មនុស្សលោកទេ។ (អេសាយ ១៤:២៧) បើលោកអ្នកចង់បានសេចក្ដីបញ្ជាក់ថែមទៀតនោះ សូមអញ្ជើញមើលសៀវភៅដែលបោះពុម្ពដោយសមាគមប៉មយាមខាងព្រះគម្ពីរនិងខិត្តប័ណ្ណ ដូចជា *ព្រះគម្ពីរ—បន្ទូលនៃព្រះឬក៏ពាក្យសំដីនៃមនុស្ស?* និងសៀវភៅ *តើមានព្រះអាទិទេពដែលយកចិត្តទុកដាក់នឹងអ្នកឬទេ?* (ជាភាសាអង់គ្លេស)

## តើតាមរបៀបណាដែលខ្ញុំអាចរៀនចេះឆ្លើយសំនួរនានាអំពីព្រះគម្ពីរបាន?

លោកអ្នកត្រូវតែសិក្សាហើយរំពឹងគិតអំពីព្រះគម្ពីរ ហើយដំណាលគ្នានោះត្រូវអធិស្ឋានសុំឱ្យវិញ្ញាណបរិសុទ្ធរបស់ព្រះជួយដឹកនាំលោកអ្នកដែរ។ (សុភាសិត ១៥:២៨; លូកា ១១:៩–១៣) ព្រះគម្ពីរបានចែងថា: «តែបើអ្នករាល់គ្នាណាមួយខ្វះប្រាជ្ញា មានតែសូមដល់ព្រះ ដែលទ្រង់ប្រទានដល់មនុស្សទាំងអស់ដោយសទ្ធា ឥតបន្ទោសផង នោះទ្រង់នឹងប្រទានឱ្យ»។ (យ៉ាកុប ១:៥) ម្យ៉ាងទៀតនោះ មានគ្រឿងជំនួយជាច្រើនក្នុងការសិក្សាព្រះគម្ពីរដែលមានប្រយោជន៍នឹងពិចារណា។ ជាធម្មតា មនុស្សយើងត្រូវការជំនួយពីអ្នកដទៃដែរ ដូចជាពេលដែលលោកភីលីពបានជួយបង្រៀនអ្នកស្រុកអេធីយ៉ូពីម្នាក់។ (កិច្ចការ ៨:២៦–៣៥) ស្មរបន្ទាល់ព្រះយេហូវ៉ាជួយបង្រៀនព្រះគម្ពីរដោយឥតគិតថ្លៃ ជាមួយនឹងមនុស្សណាដែលចាប់អារម្មណ៍នៅក្នុងផ្ទះរបស់អ្នកនោះ។ អញ្ជើញសូមសិក្សាព្រះគម្ពីរដោយសេរី។

## ហេតុអ្វីបានជាមនុស្សជាច្រើនប្រឆាំងនឹងស្មរបន្ទាល់ព្រះយេហូវ៉ា ហើយប្រាប់ខ្ញុំកុំឱ្យសិក្សាជាមួយនឹងពួកគេនោះ?

គឺមានការប្រឆាំងចំពោះការផ្សាយរបស់ព្រះយេស៊ូ ហើយទ្រង់មានបន្ទូលថាអ្នកកាន់តាមទ្រង់នឹងត្រូវបានគេប្រឆាំងដែរ។ កាលដែលអ្នកខ្លះបានចាប់អារម្មណ៍នឹងការបង្រៀនរបស់ព្រះយេស៊ូ នោះអ្នកប្រឆាំងខាងសាសនាបានចោទប្រកាន់ថា: «អ្នករាល់គ្នាត្រូវបញ្ឆោតដែរឬ? តើមានអ្នកឯណាក្នុងពួកនាម៉ឺន ឬក្នុងពួកផារិស៊ី ដែលជឿដល់អ្នកនោះឬទេ?» (យ៉ូហាន ៧:៤៦–៤៨; ១៥:២០) មនុស្សជាច្រើនដែលទូន្មានលោកអ្នកកុំសិក្សាជាមួយនឹងស្មរបន្ទាល់ព្រះយេហូវ៉ា គឺមិនទាន់ដឹងអំពីពួកគេយ៉ាងត្រឹមត្រូវនៅឡើយទេ ឬក៏មានចិត្តប្រកាន់នឹងពួកគេ។ សូមអញ្ជើញសិក្សាជាមួយនឹងស្មរបន្ទាល់ព្រះយេហូវ៉ាផ្ទាល់ខ្លួន ហើយពិនិត្យមើលដោយខ្លួនឯងចុះ ថាតើតម្រិះវិជ្ជានិងការយល់ខាងព្រះគម្ពីររបស់អ្នកនឹងត្រូវបានចម្រើនឡើងឬក៏អត់។–ម៉ាថាយ ៧:១៧–២០

## ហេតុអ្វីបានជាស្មរបន្ទាល់ព្រះយេហូវ៉ាទៅផ្សាយដល់មនុស្សដែលមានសាសនារួចហើយនោះ?

ដោយធ្វើយ៉ាងនេះ ពួកគេយកគម្រាប់តាមព្រះយេស៊ូ។ ទ្រង់បានយាងទៅផ្សាយដល់ពួកយូដា។

ពួកយូដានោះមានសាសនារបស់គេរួចទៅហើយ ប៉ុន្តែ
តាមរបៀបជាច្រើនសាសនានោះបានបែរចេញពីបន្ទូលរបស់ព្រះ ។ (ម៉ាថាយ ១៥:១–៩)
គ្រប់ៗសាសន៍មានសាសនាប្រភេទផ្សេងៗគ្នា ទោះជាសាសនាដែលគេហៅថាជាគ្រីស្ទាន
ឬក៏មិនមែនគ្រីស្ទានក៏ដោយ ។
ការដែលមនុស្សត្រូវតែកាន់តាមជំនឿដែលស្របនឹងបន្ទូលរបស់ព្រះអង្គផ្ទាល់នោះមានសារៈសំខាន់ណាស់ ។
ហើយសេចក្ដីខ្នះខ្នែងរបស់ស្មរបន្ទាល់ព្រះយេហូវ៉ាដើម្បីជួយគេឱ្យធ្វើយ៉ាងនេះ
គឺការដែលសម្ដែងនូវសេចក្ដីស្រឡាញ់ដល់អ្នកជិតខាងពិតមែន ។

## តើស្មរបន្ទាល់ព្រះយេហូវ៉ាជឿថា សាសនារបស់គេជាសាសនាត្រឹមត្រូវតែមួយឬ?

អ្នកណាក៏ដោយដែលកាន់សាសនាខ្លួនយ៉ាងស៊ប់ចិត្តគួរតែគិតថាជាសាសនាត្រឹមត្រូវ ។ បើមិនមែនអ៊ីចឹងទេ
ហេតុអ្វីបានជាគេទាក់ទងនឹងសាសនានោះ? ពួកគ្រីស្ទានបានត្រូវទូន្មានថា: «ចូរលមើលគ្រប់ទាំងអស់
ហើយកាន់ខ្ជាប់តាមសេចក្ដីដែលត្រឹមត្រូវ» ។ (ថែស្សាឡូនីចទី១ ៥:២១)
មនុស្សម្នាក់គួរតែធ្វើឱ្យបានប្រាកដប្រជាថា ជំនឿរបស់ខ្លួនមានមូលដ្ឋានទៅលើព្រះគម្ពីរ
ដ្បិតមានជំនឿដ៏ពិតតែមួយទេ ។ អេភេសូរ ៤:៥ បានបញ្ជាក់រឿងនេះ ដោយថែងថា÷ «មានព្រះអម្ចាស់តែ១
សេចក្ដីជំនឿតែ១ បុណ្យជ្រមុជតែ១» ។ ព្រះយេស៊ូមិនបានយល់ស្របនឹងទស្សនៈសម័យទំនើបយ៉ាងរាក់កំផែលថា
មានផ្លូវជាច្រើន សាសនាជាច្រើន ដែលគ្រប់ទាំងអស់ដឹកនាំទៅឯសេចក្ដីសង្គ្រោះនោះទេ ។ ផ្ទុយទៅវិញ
ទ្រង់មានបន្ទូលថា: «តែឯទ្វារដែលនាំទៅឯជីវិត នោះតូច ហើយចង្អៀតវិញ
ក៏មានមនុស្សតិចណាស់ដែលរកផ្លូវនោះឃើញ» ។ ស្មរបន្ទាល់ព្រះយេហូវ៉ាជឿថា គេបានរកឃើញផ្លូវនោះហើយ ។
បើមិនអ៊ីចឹងទេ ពួកគេនឹងស្វែងរកសាសនាមួយទៀតហើយ ។– ម៉ាថាយ ៧:១៤

## តើពួកគេជឿថា គេជាពួកតែមួយគត់ដែលនឹងត្រូវបានសង្គ្រោះឬ?

មិនមែនទេ ។ មនុស្សរាប់លាននាក់ដែលបានរស់នៅក្នុងកំឡុងពេលជាច្រើនសតវត្សកន្លងមកនោះ
ហើយដែលមិនមែនជាស្មរបន្ទាល់ព្រះយេហូវ៉ានោះទេ នឹងមានជីវិតម្ដងទៀតតាមដំណើររស់ឡើងវិញ
ហើយនឹងមានឱកាសនឹងទទួលជីវិតបាន ។ មនុស្សជាច្រើននាក់ដែលកំពុងរស់សព្វថ្ងៃនេះ
ប្រហែលនឹងតាំងចិត្តគាំទ្រសេចក្ដីសុចរិតនិងសេចក្ដីពិតមុនគ្រា «វេទនាជាខ្លាំងណាស់»
ហើយអ្នកនោះនឹងទទួលសេចក្ដីសង្គ្រោះបាន ។ ម្យ៉ាងទៀតនោះព្រះយេស៊ូមានបន្ទូលថា
យើងមិនត្រូវថ្កោលទោសមនុស្សគ្នាឯងឡើយ ។ មនុស្សយើងមើលតែអាការក្រៅប៉ុណ្ណោះទេ តែឯចំណែកព្រះ
នោះទ្រង់ទតមើលចិត្តវិញ ។ ព្រះទ្រង់ទតឃើញយ៉ាងច្បាស់ត្រឹមត្រូវ ហើយជំនុំជំរះដោយមេត្តាករុណាផង ។
ព្រះទ្រង់បានប្រគល់សេចក្ដីជំនុំជំរះទៅព្រះយេស៊ូ មិនមែនប្រគល់ឱ្យយើងនោះទេ ។– ម៉ាថាយ ៧:១–៥; ២៤:២១;
២៥:៣១

## តើវិភាគទានអ្វីដែលតម្រូវពីមនុស្សដែលរួមប្រជុំនឹងស្មរបន្ទាល់ព្រះយេហូវ៉ានោះ?

ចំណែកឯវិភាគទានខាងលុយនោះ សាវ័កប៉ុលមានប្រសាសន៍ថា: «ចូរឱ្យគ្រប់គ្នាធ្វើតាមដែលសំរេចក្នុងចិត្តចុះ មិនមែនដោយស្ដាយ ឬដោយបង្ខំឡើយ ដ្បិតព្រះទ្រង់ស្រឡាញ់ដល់អ្នកណាដែលថ្វាយដោយអំណរ» ។ (កូរិនថូសទី២ ៩:៧) នៅក្នុងសាលព្រះរាជាណាចក្រនិងទីប្រជុំសំរាប់សន្និបាតរបស់ស្មរបន្ទាល់ព្រះយេហូវ៉ា មិនដែលរៃលុយឡើយ ។ ប្រអប់បានត្រូវដាក់នៅកន្លែងនានា ដើម្បីធ្វើឱ្យស្រួលសម្រាប់អ្នកណាដែលមានចិត្តប្រាថ្នាចង់ថ្វាយវិភាគទាន ឱ្យថ្វាយទៅបាន ។ គ្មានអ្នកណាដឹងចំនួនដែលអ្នកដទៃថ្វាយទេ ។ អ្នកខ្លះអាចថ្វាយច្រើនជាងអ្នកដទៃ តែអ្នកខ្លះទៀតប្រហែលជាមិនអាចថ្វាយអ្វីឡើយ ។ ព្រះយេស៊ូបានបង្ហាញទស្សនៈត្រឹមត្រូវ ពេលដែលទ្រង់មានបន្ទូលអំពីប្រអប់វិភាគទាននៅឯព្រះវិហារក្នុងទីក្រុងយេរូសាឡិម ហើយអំពីមនុស្សដែលថ្វាយអំណោយនៅទីនោះ: អ្វីដែលសំខាន់នោះគឺជាសមត្ថភាពនិងសទ្ធាចិត្តចង់ថ្វាយ មិនមែនចំនួនលុយនោះទេ ។–លូកា ២១:១–៤

## បើសិនជាខ្ញុំទៅជាស្មរបន្ទាល់ម្នាក់របស់ព្រះយេហូវ៉ា តើនោះតម្រូវឱ្យខ្ញុំទៅផ្សព្វផ្សាយដូចពួកគេធ្វើដែរឬទេ?

កាលណាមនុស្សណាម្នាក់ត្រូវបានពោរពេញទៅដោយតម្រិះវិជ្ជាអំពីសួនមនោរម្យនៅលើផែនដីដែលបានសន្យាមក នៅក្រោមព្រះរាជាណាចក្ររបស់ព្រះគ្រីស្ទ អ្នកនោះមានចិត្តចង់ចែកដំណឹងនេះជាមួយអ្នកដទៃដែរ ។ លោកអ្នកនឹងមានចិត្តចង់ធ្វើដូច្នោះដែរ ។ នេះជាដំណឹងល្អណាស់ ។–កិច្ចការ ៥:៤១, ៤២

ការប្រព្រឹត្តបែបនេះជាវិធីសំខាន់មួយដែលបង្ហាញ លោកអ្នកជាសិស្សរបស់ព្រះយេស៊ូគ្រីស្ទ ។ នៅក្នុងព្រះគម្ពីរ ព្រះយេស៊ូបានត្រូវហៅថា «ស្មរបន្ទាល់ស្មោះត្រង់ ហើយពិតប្រាកដ» ។ កាលដែលទ្រង់គង់នៅលើផែនដីនៅឡើយ ទ្រង់បានផ្សាយដោយមានបន្ទូលថា: «នគរស្ថានសួគ៌ជិតមកដល់ហើយ» ហើយទ្រង់បានចាត់សិស្សរបស់ទ្រង់ឱ្យធ្វើដូចគ្នាដែរ ។ (វិវរណៈ ៣:១៤; ម៉ាថាយ ៤:១៧; ១០:៧) បន្ទាប់មក ព្រះយេស៊ូបានបញ្ជាអ្នកកាន់តាមទ្រង់ថា: «ដូច្នេះ ចូរទៅបញ្ចុះបញ្ចូលឱ្យមានសិស្សនៅគ្រប់ទាំងសាសន៍ ព្រមទាំង . . . បង្រៀនឱ្យគេកាន់តាមគ្រប់ទាំងសេចក្ដី ដែលខ្ញុំបានបង្គាប់មកអ្នករាល់គ្នាផង» ។ ទ្រង់ថែមទាំងទាយទុកថា មុនទីបញ្ចប់នឹងមកដល់នេះ «ដំណឹងល្អនេះ ដែលសំដែងពីនគរ នឹងត្រូវប្រកាសប្រាប់ទូទៅគ្រប់ក្នុងលោកីយ ទុកជាទីបន្ទាល់ដល់អស់ទាំងសាសន៍» ។–ម៉ាថាយ ២៤:១៤; ២៨:១៩, ២០

គឺមានវិធីជាច្រើនដើម្បីផ្សាយប្រកាសដំណឹងល្អនេះ ។ ការសន្ទនាជាមួយនឹងពួកសំឡាញ់និងអ្នកធ្លាប់ស្គាល់គ្នាជាញឹកញាប់អាចបើកផ្លូវឱ្យធ្វើការប្រកាសនេះបាន ។ អ្នកខ្លះធ្វើការផ្សាយដោយសរសេរសំបុត្រទៅគេ ឬក៏ដោយប្រើទូរស័ព្ទដែរ ។ អ្នកខ្លះទៀតធ្វើប្រកាសនវត្តតាមប្រៃសណីយ៍ ដែលមានរឿងដែលគេគិតថាអ្នកដែលគេស្គាល់មាក់នឹងចាប់ចិត្តជាពិសេសនោះ ។

ដោយមានចិត្តប្រាថ្នានឹងជួបមនុស្សទាំងអស់
ស្មរបន្ទាល់ព្រះយេហូវ៉ាដើរពីផ្ទះមួយទៅផ្ទះមួយដើម្បីនឹងផ្សាយដំណឹងល្អនេះ ។

នៅក្នុងព្រះគម្ពីរមានសេចក្តីអញ្ជើញដ៏រាក់ទាក់នេះ: «ព្រះវិញ្ញាណ នឹងប្រពន្ធថ្មោងថ្មីពោលថា: <អញ្ជើញមក>!
ហើយអ្នកណាដែលឮ ក៏ថា: < អញ្ជើញមក>! ដែរ អ្នកណាដែលស្រេកនោះមានតែមក
ហើយអ្នកណាដែលចង់បាន មានតែយកទឹកជីវិតនោះចុះ ឥតចេញថ្លៃទេ» ។ (វិវរណៈ ២២:១៧)
ការប្រាប់អ្នកដទៃអំពីផែនដីមនោរម្យនិងអំពីពរដ៏ល្អនោះ ជាការដែលត្រូវធ្វើដោយស្ម័គ្រចិត្ត
ពីចិត្តដែលពោរពេញទៅដោយសេចក្តីប្រាថ្នាចង់ចែកដំណឹងល្អនេះជាមួយអ្នកដទៃ ។

យើងយល់ថា លោកអ្នកប្រាកដជាមានសំនួរឯទៀតអំពីស្មរបន្ទាល់ព្រះយេហូវ៉ា និងអំពីជំនឿរបស់គេហើយ ។
ប្រហែលជាសំនួរខ្លះនោះអាចនាំអោយមានវាទប្បដិវាទ ។ យើងចង់ឆ្លើយសំនួរទាំងអស់របស់លោកអ្នក ។
នៅក្នុងសៀវភៅស្តើងនេះមិនមានកន្លែងច្រើនទេ ។
ហេតុដូច្នេះហើយបានជាយើងអញ្ជើញលោកអ្នកសួរសំនួរទាំងនេះ
ដល់ស្មរបន្ទាល់ព្រះយេហូវ៉ានៅជិតទីកន្លែងរបស់លោកអ្នក ។ អ្នកអាចសួរគេនៅឯកិច្ចប្រជុំរបស់គេ
នៅសាលព្រះរាជាណាចក្រ ឬកាលដែលគេទៅជួបលោកអ្នកនៅតាមផ្ទះរបស់អ្នក ។
ឬក៏លោកអ្នកអាចផ្ញើសំនួររបស់លោកអ្នក ទៅសមាគមប៉មយាម (Watch Tower)
ដោយប្រើអាស័យដ្ឋានពីបញ្ជីនៅខាងក្រោមនេះ ។

Copyright © 2004 Watchtower Bible and Tract Society of Pennsylvania. All rights reserved.